ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ១១៩៨ ឧ.រ.ថ.ធរ.អប

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០...

## អាជ្ញាប័ណ្ណស្វែងរុករក
( លើកទី២ )

---

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែលោហៈ នៅតំបន់លំផាត់ ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងក្រុមហ៊ុន Cambo Cana Kiri Development Ltd ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករកលេខ៤៣៧ឧរថ.ធរ.អប ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨
- សេចក្តីកែតម្រូវលេខ០០១ នៃកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់លំផាត់ ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨
- សេចក្តីកែតម្រូវលេខ០០២ នៃកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់លំផាត់ ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន ចុះថ្ងៃទី 16 DEC 2009

### សម្រេច

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន HOANG ANH-RATTANAKIRI CO., LTD មានការិយាល័យស្នាក់ការ តាមបណ្តោយផ្លូវជាតិលេខ៧៨ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់លំផាត់ ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី លើផ្ទៃដី ១៥៤ (មួយរយហាសិបបួន) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោនេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
| --- | --- | --- | --- | --- | --- |
| A | $7\ 46^{000}$ | $15\ 24^{000}$ | C | $7\ 57^{000}$ | $15\ 10^{000}$ |
| B | $7\ 57^{000}$ | $15\ 24^{000}$ | D | $7\ 46^{000}$ | $15\ 10^{000}$ |

<u>ប្រការ២</u> : ក្រុមហ៊ុនត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយចាំបាច់អនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

<u>ប្រការ៣</u> : អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ មុនផុតកំណត់៩០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ។

<u>ប្រការ៤</u> : ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ អាជ្ញាប័ណ្ណនេះនឹងត្រូវព្យួរទុក ឬដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

<u>ប្រការ៥</u> : អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តរតនគិរី និងក្រុមហ៊ុន HOANG ANH-RATTANAKIRI CO., LTD ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារកិច្ចរៀងៗខ្លួន ។

<u>ប្រការ៦</u> : អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសាធារណការ និង ដឹកជញ្ជូន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងធនធានទឹក និង ឧតុនិយម
- ទីចាត់ការគយ និងរដ្ឋាករ
- សាលាខេត្តព្រៃវែង
- សាលាស្រុកពាមជរ
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម